# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

### ក្រុមហ៊ុន សេរី (ខេមបូឌា) ហ្គាម៉ិន ខូអិលធីឌី

កិច្ចព្រមព្រៀង

រវាង

ក្រុមហ៊ុន សេរី (ខេមបូឌា) ហ្គាម៉ិន ខូអិលធីឌី ជាមួយតំណាងកម្មករ និងសហជីព
ប្រចាំក្រុមហ៊ុន

ឆ្នាំពីរពាន់ម្ភៃ ខែ មេសា ថ្ងៃទី ១៤ វេលាម៉ោង២ និង ៣០នាទីថ្ងៃត្រង់នៅការិយាល័យក្រុមហ៊ុន សេរី (ខេមបូឌា) ហ្គាម៉ិន ខូអិលធីឌី មានកិច្ចប្រជុំពិភាក្សា រវាងតំណាងក្រុមហ៊ុន ប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីព សម្លេងយុវជនខ្មែរ ប្រចាំរោងចក្រ។ ក្រោយពីបានប្រជុំពិភាក្សា ភាគីទាំងពីរបានយល់ព្រមព្រៀងគ្នាដូចខាងក្រោមៈ

១-ភាគីទាំងពីរយល់ព្រមព្យួរការងាររយៈពេលពីរខែចំពោះកម្មករនិយោជិតមួយចំនួន ៦២២ នាក់ មានផ្នែកដេរ ផ្នែកវេចខ្ចប់ ផ្នែកពិនិត្យគុណភាព ផ្នែកជាងម៉ាស៊ីន ផ្នែកឃ្លាំង និងបុគ្គលិកការិយាល័យ ដោយគិតចាប់ ពីថ្ងៃទី ២៧ខែមេសាឆ្នាំ២០២០ រហូតដល់ ថ្ងៃទី២៦ខែមិថុនាឆ្នាំ២០២០ ដោយសារអ្នកបញ្ជាទិញផ្អាកការបញ្ជាទិញ ព្រោះប្រទេសទាំងនោះរងផលប៉ះពាល់ពីជម្ងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ ខូវីដ១៩ (COVID19)។

២-ភាគីកម្មករនិយោកជិតយល់ព្រមទទួលប្រាក់ឧបត្ថម្ភ ៣០ដុល្លារអាមេរិក ពីភាគីនិយោជក និង ៤០ ដុល្លារអាមេរិកដែរជាប្រាក់ឧបត្ថម្ភពិសេសរបស់រាជរដ្ឋាភិបាលដូច្នេះជាសរុបកម្មករនិយោជិតម្នាក់ទទួលបាន៧០ដុល្លារអាមេរិកក្នុង១ ខែសំរាប់រយៈពេលព្យួរការងារនេះ។

៣-ក្រុមហ៊ុននិងបើកជូនប្រាក់ឧបត្ថម្ភ៣០ ដុល្លារអាមរិកនេះជូនកម្មករនិយោជិត១ខែម្តង។

៤-បងប្អូនត្រូវត្រលប់ចូលមកធ្វើការវិញនាថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០២០ ក្នុងករណីបងប្អូន កម្មករមិនបានចូលធ្វើការតាមការកំណត់នេះទេ ក្រុមហ៊ុននឹងអនុវត្តន៍តាមច្បាប់ស្តីពីការងារនិងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន។

កិច្ចព្រមព្រៀងនេះ ចាប់អនុវត្តន៍និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ០៧ រោច ខែ ចែត្រ ឆ្នាំជូត ទោស័ក២៥៦៣

កំពង់ស្ពឺ ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០២០

**ស្នាមមេដៃតំណាងកម្មករនិយោជិត**

១-
២-
៣-
៤- Kaw Sineth
៥- Yong Choeun
៦-
៧-

**តំណាងក្រុមហ៊ុន**

ក្រុមហ៊ុន សេរី (ខេមបូឌា) ហ្គាម៉ិន ខូ អិលធីឌី
CERIE (CAMBODIA) GARMENT Co., Ltd.
KINGDOM OF CAMBODIA